ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តសៀមរាប
លេខ: ៤៨៥ /២១ ណ.ស.ក

# អាជ្ញាបណ្ណទេសចរណ៍
# TOURISM LICENSE

អភិបាល នៃគណៈអភិបាលខេត្ត



អនុញ្ញាតជូន : លោកស្រី ភឿក សុផល Mrs. PERK SOPHAL ( ខ្មែរ )
អាសយដ្ឋាន : ភូមិមណ្ឌល១ សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប
ប្រភេទអាជីវកម្ម : ភោជនីយដ្ឋាន ចំនួន៨០កៅអី ( បន្ត )
ឈ្មោះអាជីវកម្ម : អាហារដ្ឋាន ផ្ទះបាយខ្មែរ ភឿក AHARATHAN PHTEAH BAI KHMER PERK
សុពលភាពចាប់ពី : ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២១ ដល់ ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២២

ម្ចាស់អាជីវកម្ម ត្រូវមកដាក់ពាក្យបន្តអាជ្ញាបណ្ណទេសចរណ៍ក្នុងរយៈពេល៣០ថ្ងៃ មុនហួសសុពលភាព។

ថ្ងៃ ... ខែ ... ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥
ខេត្តសៀមរាប ថ្ងៃទី ... ខែ ... ឆ្នាំ២០២១

អភិបាលខេត្ត

ពៅ ពិសិដ្ឋ

## ម្ចាស់អាជីវកម្មត្រូវគោរពតាមគោលការណ៍ លក្ខខណ្ឌ និងមានភារកិច្ចដូចខាងក្រោម៖

១. ក្នុងដំណើរការប្រកបអាជីវកម្ម ម្ចាស់ត្រូវអនុវត្តតាមច្បាប់របស់រដ្ឋជាធរមាន តាមការណែនាំ និងលិខិតបទបញ្ញត្តិរបស់ក្រសួង និងមិនធ្វើអាជីវកម្មផ្សេងៗទៀតដោយគ្មានការអនុញ្ញាត

២. ហាមដាច់ខាតដាក់លក់ ឬប្រើប្រាស់គ្រឿងញៀន និងជួញដូរផ្លូវភេទគ្រប់រូបភាព

៣. ត្រូវធានាមិនឲ្យមានការប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ បរិស្ថាន សុវត្ថិភាព និងទំនៀមទម្លាប់ ប្រពៃណីជាតិ

៤. ក្នុងករណីដំណើរការអាជីវកម្ម បើមានការផ្ទេរឈ្មោះម្ចាស់ ឬអ្នកគ្រប់គ្រង ឬប្តូរឈ្មោះទៅឲ្យអ្នកផ្សេង ម្ចាស់អាជីវកម្មត្រូវជូនដំណឹងមករដ្ឋបាលខេត្តសៀមរាប ឬមន្ទីរទេសចរណ៍ឲ្យបានមុនយ៉ាងតិចពីរសប្តាហ៍

៥. សហការ និងរាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ចនូវបាតុភាពអសកម្ម ដែលបណ្តាលឲ្យប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាពភ្ញៀវ និងបុគ្គលិករបស់ម្ចាស់អាជីវកម្មឲ្យបាន ២៤ម៉ោង លើ ២៤ម៉ោង

៦. បន្ទប់ទឹក បង្គន់ត្រូវមានសម្ភារៈគ្រប់គ្រាន់ និងមានអនាម័យល្អ ហើយត្រូវមានអ្នកទទួលខុសត្រូវថែទាំ សម្អាតជាប្រចាំ

៧. ធានាថែទាំ សម្អាតនូវរាល់គ្រប់ផ្នែកទាំងអស់របស់ភោជនីយដ្ឋានឲ្យបានល្អ និងមានអនាម័យខ្ពស់បំផុត

៨. លក្ខណៈនៃការតុបតែងកែលម្អ និងការបំពាក់សម្ភារៈបរិក្ខាត្រូវរក្សាឲ្យបាននូវទំនៀមទម្លាប់ ប្រពៃណី វប្បធម៌ជាតិ ព្រមទាំងរក្សាតម្លៃអត្តសញ្ញាណជាតិខ្មែរ

៩. ចូលរួមយុទ្ធនាការ ទេសចរម្នាក់ដាំដើមឈើ១ដើម ដើម្បីគាំទ្រ និងចូលរួមកាត់បន្ថយផលប៉ះពាល់នៃការកើនឡើងកម្តៅផែនដី

១០. ចូលរួមផ្សព្វផ្សាយដល់បុគ្គល និងទេសចរក្នុងការការពារ ថែរក្សាអនាម័យ បរិស្ថាន បង្កើតការយល់ដឹងអំពីវិធានការកាត់បន្ថយការប្រើប្រាស់ថាមពលអគ្គិសនី ទឹក និងការគ្រប់គ្រងកាកសំណល់

១១. គាំទ្រ និងចូលរួមយុទ្ធនាការឃោសនាផ្សព្វផ្សាយ កម្ពុជា៖ ព្រះរាជាណាចក្រអច្ឆរិយៈ និងចលនាប្រឡងប្រណាំង "ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ និងបដិសណ្ឋារកិច្ចល្អ" និងជំរុញចលនាទេសចរក្នុងស្រុកឲ្យមានកំណើនខ្ពស់

១២. មិនត្រូវដំឡើងថ្លៃម្ហូបអាហារនៅពេលមាន បុណ្យជាតិ អន្តរជាតិ និងព្រឹត្តិការណ៍ផ្សេងៗ

១៣. គោរពតាមសេចក្តីណែនាំលេខ ០០៨ សណន ស្តីពីការអនុវត្តយុទ្ធនាការ (ភោជនីយដ្ឋាន អាហារដ្ឋានស្អាត និងគ្មានសំរាមជាក្រដាស)

១៤. គោរពតាមសេចក្តីណែនាំរបស់ក្រសួងទេសចរណ៍ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីបរិស្ថានគ្មានផ្សែងបារីដល់អ្នកគ្រប់គ្រង ឬម្ចាស់អាជីវកម្មសេវាកម្មទេសចរណ៍ទូទាំងព្រះរាជាណាចក្រកម្ពុជា

១៥. ត្រូវដាក់ព្យួរអាជ្ញាបណ្ណទេសចរណ៍ នៅកន្លែងដែលងាយស្រួលមើលឃើញច្បាស់ក្នុងទីបរិវេណធ្វើអាជីវកម្ម "ងាយស្រួលដល់សមត្ថកិច្ចគ្រប់ស្ថាប័នចុះត្រួតពិនិត្យ"។